




វត្ថុបំណង
រៀនឲ្យដឹងថា
តើសិស្សរបស់ព្រះយេស៊ូមានលក្ខណសម្បត្តិយ៉ាងណាខ្លះ
តើការសង្គ្រោះនិងការបង្កើតសិស្សមានភាពខុសប្លែកគ្នាត្រង់ណា
ដើម្បីឲ្យអ្នកមានចិត្តខ្នះខ្នែងចង់រីកចម្រើនជាសិស្សរបស់ព្រះយេស៊ូ
ហើយចង់បង្កើតសិស្សតទៅទៀតតាមបញ្ជារបស់ព្រះអង្គ។

១.ព្រះយេស៊ូត្រាស់ហៅយើងឲ្យមកធ្វើជាសិស្សរបស់ព្រះអង្គ
1. JESUS CALLED US TO BE HIS DISCIPLES
ម៉ាថាយ ១១:២៨-៣០
២៨ «អស់អ្នកដែលនឿយហត់និងមានបន្ទុកធ្ងន់អើយ!
ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបាន សំរាក។
២៩ ចូរយកនឹមរបស់ខ្ញុំដាក់លើអ្នករាល់គ្នា
ហើយ រៀនពីខ្ញុំ ទៅអ្នករាល់គ្នាមុខជាបាន ស្ងប់ចិត្ត មិនខាន
ដ្បិតខ្ញុំស្លូតនិងមានចិត្តសុភាព។
៣០ នឹមរបស់ខ្ញុំស្រួលហើយបន្ទុកដែលខ្ញុំដាក់លើអ្នករាល់គ្នាក៏ស្រាលដែរ»។

ការត្រាស់ហៅពីរបែបរបស់ព្រះយេស៊ូ TWO TYPES OF JESUS' CALLING
ការត្រាស់ហៅមកធ្វើជាអ្នកជឿព្រះយេស៊ូ( ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសំរាក )
ការត្រាស់ហៅមកធ្វើជាសិស្សព្រះយេស៊ូ( រៀនពីខ្ញុំទៅអ្នករាល់គ្នាមុខជាបានស្ងប់ចិត្ត )។



១.ការត្រាស់ហៅមកធ្វើជាអ្នកជឿព្រះយេស៊ូ( the call to be believers of Jesus )
អ្នកជឿព្រះយេស៊ូនឹងបានទទួលការសម្រាក( rest )ឬបានទទួលការសង្គ្រោះ( salvation )
២.ការត្រាស់ហៅមកធ្វើជាសិស្សព្រះយេស៊ូ( the call to be disciples of Jesus )
សិស្សព្រះយេស៊ូនឹងបានទទួលនឹមស្រួល( easy yoke )គឺការបង្រៀនស្រួល( easy teaching )
បន្ទុកស្រាល( light burden )គឺបទបញ្ញាឬក្រឹត្យវិន័យស្រាល( light command, light law )។

២.សិស្សរបស់ព្រះយេស៊ូនឹងរីកចម្រើនឡើងគ្រប់វិស័យឆ្ពោះទៅកាន់ព្រះគ្រិស្ដ
2. A DISCIPLE OF JESUS WILL GROW UP IN EVERY WAY INTO CHRIST
អេភេសូ ៤:១៤-១៦
១៤ ដូច្នេះ យើងមិនមែនជាកូនក្មេងដែលរេរា
ត្រូវខ្យល់នៃគោលលទ្ធិនានាផាត់ចុះផាត់ឡើងនោះទៀតឡើយ
ហើយក៏លែងចាញ់បោកឬចាញ់កលល្បិចមនុស្សដែលពូកែនាំឲ្យវង្វេងនោះទៀតដែរ។
១៥ ផ្ទុយទៅវិញ បើយើងប្រព្រឹត្តតាមសេចក្ដីពិតដោយចិត្តស្រឡាញ់
យើងនឹង បានចំរើនឡើង គ្រប់វិស័យទាំងអស់ឆ្ពោះទៅកាន់ព្រះគ្រិស្ដជាសិរសា
១៦ គឺព្រះអង្គហើយដែលធ្វើឲ្យព្រះកាយទាំងមូលបានផ្គុំគ្នានិងភ្ជាប់គ្នាឡើងយ៉ាងមាំ
ដោយសារ សន្លាក់ឆ្អឹងទាំងប៉ុន្មាន ដែលបម្រើព្រះកាយ
តាមកម្រិតសមត្ថភាពរបស់សរីរាង្គនីមួយៗ
ដើម្បីឲ្យព្រះកាយនោះចម្រើននិងកសាងឡើងក្នុងសេចក្ដីស្រឡាញ់។

អាថ៌កំបាំងនៃការបង្កើតសិស្ស THE MYSTERY OF DISCIPLESHIP
មុនពេលព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាង ទ្រង់ជ្រើសរើសសិស្សដោយផ្ទាល់ព្រះអង្គ
ទ្រង់យកសិស្សមកនៅជាមួយ ទ្រង់រៀបចំសិស្សជាក្រុម ទ្រង់បង្រៀនសិស្សដោយគំរូជាក់ស្តែង
ទ្រង់បើកឱកាសឲ្យសិស្សធ្វើការជាមួយ ទ្រង់ចាត់សិស្សមួយក្រុមពីរនាក់ៗឲ្យចេញទៅតាមភូមិ
ទ្រង់ប្រជុំសិស្សដើម្បីស្តាប់របាយការ ទ្រង់កែលម្អសិស្ស ទ្រង់បង្រៀនសិស្សបន្ថែមទៀត ។ល ។
ព្រះគ្រិស្តមិនចង់ឃើញសិស្សរបស់ព្រះអង្គ ( his disciples ) នៅដូចជាកូនក្មេងដែលចេះតែរេរា
តាមការបង្រៀនប្លែកៗ និងនៅតែចាញ់កលល្បិចបោកបញ្ឆោតរបស់គ្រូក្លែងក្លាយនោះឡើយ ។
ព្រះគ្រិស្តចង់ឃើញសិស្សរបស់ព្រះអង្គប្រព្រឹត្តតាមសេចក្តីពិតដោយចិត្តស្រឡាញ់
ហើយរីកចម្រើនឡើងគ្រប់វិស័យឆ្ពោះទៅកាន់ព្រះគ្រិស្តដែលជាសិរសារបស់ក្រុមជំនុំ ។
នៅសម័យនេះ ព្រះគ្រិស្តបង្កើតសិស្សតាមរយៈអ្នកបង្កើតសិស្ស ( disciple makers )
នៅតាមក្រុមជំនុំមូលដ្ឋានដែលមានតួនាទីដូចសន្លាក់ឆ្អឹង ( joints, ligaments )
ដែលតភ្ជាប់ឆ្អឹង ( bones ) ជាមួយគ្នាដើម្បីទ្រទ្រង់រូបកាយទាំងមូល ( the whole body ) ។
សិស្សរបស់ព្រះយេស៊ូម្នាក់ប្រៀបដូចជាឆ្អឹងមួយដុំ ។ ក្រុមជំនុំប្រៀបដូចជារូបកាយទាំងមូល ។

## ៣.លក្ខណសម្បត្តិរបស់សិស្សព្រះយេស៊ូ

### 3. THE CHARACTERISTICS OF A DISCIPLE OF JESUS

សិស្សរបស់ព្រះយេស៊ូមានលក្ខណសម្បត្តិប្រាំពីរយ៉ាងដូចតទៅ៖

- ស្រឡាញ់ព្រះបន្ទូលរបស់ព្រះគ្រិស្ត Loves the words of Christ
- ស្រឡាញ់ព្រះយេស៊ូជាងគ្រួសារខ្លួន Loves Jesus more than his family
- ស្រឡាញ់ព្រះយេស៊ូជាងទ្រនំសុខខ្លួន Loves Jesus more than his comfort
- ស្រឡាញ់ព្រះយេស៊ូជាងទ្រព្យសម្បត្តិខ្លួន Loves Jesus more than his wealth
- ស្រឡាញ់គ្នាទៅវិញទៅមក Loves one another
- ស្រឡាញ់ការពហុគុណ Loves multiplication
- ស្រឡាញ់ការរៀបផែនការឈ្លាសវៃ Loves SMART Planning

ទាល់តែទទួលការថែបំប៉នពី«អ្នកបង្កើតសិស្ស»ទើបសិស្សរបស់ព្រះយេស៊ូម្នាក់ៗមានឱកាសរីកចម្រើនឡើងគ្រប់វិស័យឆ្ពោះទៅកាន់ព្រះគ្រិស្តជាសិរសានៃក្រុមជំនុំ។( អេភេសូ ៤:១១-១៥ )

## ក.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ព្រះបន្ទូលរបស់ព្រះគ្រិស្ត

### A. A DISCIPLE OF JESUS LOVES THE WORDS OF CHRIST

យ៉ូហាន ៨:៣១

៣១ ពេលនោះព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ជនជាតិយូដាដែលបានជឿលើព្រះអង្គថា៖ «ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹង ពាក្យរបស់ខ្ញុំ អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។

ស្រឡាញ់ព្រះបន្ទូលរបស់ព្រះគ្រិស្ត LOVE THE WORDS OF CHRIST
គឺឲ្យតម្លៃព្រះបន្ទូលរបស់ព្រះគ្រិស្ត(Esteem the words of Christ)
ខ្ពស់ជាងពាក្យរបស់ព្យាការី(more than the words of the prophets)
ខ្ពស់ជាងពាក្យរបស់បរមគ្រូ(more than the words of the great teachers)
ខ្ពស់ជាងពាក្យរបស់មហាបុរសណាទាំងអស់(more than the words of the great men)
ហើយនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្តក្នុងគ្រប់កាលៈទេសៈ។
(and abide in the words of Christ in all circumstances)



ភស្តុតាង(EVIDENCE)នៃការស្រឡាញ់ព្រះបន្ទូលរបស់ព្រះគ្រិស្ត
សិស្សរបស់ព្រះយេស៊ូស្រឡាញ់ព្រះបន្ទូលរបស់ព្រះគ្រិស្ត( love the words of Christ )ដោយ
ស្តាប់( listen ) អាន( read ) យល់( understand ) ទទួល( accept ) ចងចាំ( remember )
ប្រតិបត្តិតាម( observe ) និងប្រកាស( preach )ព្រះបន្ទូលរបស់ព្រះគ្រិស្តជារៀងរាល់ថ្ងៃ។

ខ.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ព្រះយេស៊ូជាងគ្រួសាររបស់ខ្លួន
B. A DISCIPLE OF JESUS LOVES JESUS MORE THAN HIS FAMILY
លូកា ១៤:២៦
២៦ បើអ្នកណាចង់មកតាមខ្ញុំ
តែមិនស្រឡាញ់ ខ្ញុំ ខ្លាំងជាងឪពុកម្ដាយ ប្រពន្ធ កូន បងប្អូនប្រុសស្រី និងជីវិតខ្លួនទេ
អ្នកនោះពុំអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ។

ស្រឡាញ់ព្រះយេស៊ូជាងគ្រួសាររបស់ខ្លួន LOVE JESUS MORE THAN ONE’S FAMILY
គឺនៅតែសម្រេចចិត្តដើរតាមព្រះយេស៊ូដដែលដើម្បីឲ្យមានឱកាសរីកចម្រើនជាសិស្សព្រះអង្គ
ទោះបីជាសមាជិកគ្រួសាររបស់ខ្លួនជំទាស់( ប្រឆាំង oppose រារាំង block ឃាត់ឃាំង forbid
គំរាម threaten បៀតបៀន persecute )មិនឲ្យខ្លួនដើរតាមព្រះយេស៊ូយ៉ាងណាក៏ដោយ។
ក្រោយពីបែកចេញពីគ្រួសាររបស់ខ្លួនមួយរយៈ សិស្សម្នាក់ៗនឹងមានឱកាសវិលត្រឡប់មកវិញ
ហើយចេះស្រឡាញ់គ្រួសាររបស់ខ្លួនដូចព្រះយេស៊ូបានស្រឡាញ់គាត់ដែរ។

ខ១.សិស្សរបស់ព្រះយេស៊ូនឹងប្រឈមជាមួយការបាក់បែកគ្នាក្នុងគ្រួសារ

A DISCIPLE OF JESUS WILL FACE DIVISION IN HIS FAMILY

លូកា ១២:៥១-៥៣

៥១ កុំនឹកស្មានថាខ្ញុំមកដើម្បីផ្ដល់សន្តិភាពឲ្យផែនដីនេះឡើយ
គឺខ្ញុំបាននាំ ការបាក់បែក មកទេតើ។
៥២ ចាប់ពីពេលនេះតទៅ ឧបមាថាក្នុងផ្ទះមួយមានគ្នាប្រាំនាក់
អ្នកទាំងប្រាំនឹងត្រូវបាក់បែកគ្នា
គឺបីនាក់បែកចេញពីពីរនាក់ ពីរនាក់បែកចេញពីបីនាក់
៥៣ ឪពុកនឹងបែកចេញពីកូនប្រុស កូនប្រុសបែកចេញពីឪពុក
ម្ដាយបែកចេញពីកូនស្រី កូនស្រីបែកចេញពីម្ដាយ
ម្ដាយក្មេកបែកចេញពីកូនប្រសាស្រី កូនប្រសាស្រីបែកចេញពីម្ដាយក្មេក»។



បើយើងជឿព្រះយេស៊ូល្មមៗ សាតាំងមិនញុះញង់គ្រួសាររបស់យើងឲ្យស្អប់យើងខ្លាំងទេ តែបើយើងសម្រេចថាដើរតាមព្រះយេស៊ូយ៉ាងប្ដូរផ្ដាច់ នោះសាតាំងនឹងញុះញង់គ្រួសាររបស់យើងឲ្យស្អប់យើងជាខ្លាំង។ យើងអាចបែកចេញពីគ្រួសារមួយរយៈព្រោះតែព្រះយេស៊ូ និងដំណឹងល្អ ប៉ុន្តែព្រះអង្គនឹងប្រទានរង្វាន់ឲ្យយើងមានសមាជិកគ្រួសារថ្មីមួយជាមួយរយ។

ខ២.សិស្សរបស់ព្រះយេស៊ូនឹងទទួលសមាជិកគ្រួសារថ្មីមួយជាមួយរយ
A DISCIPLE OF JESUS WILL RECEIVE A HUNDREDFOLD FAMILY MEMBERS
ម៉ាកុស ១០:២៩-៣០
២៩ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថាអ្នកណាលះបង់ផ្ទះសម្បែង
បងប្អូនប្រុសស្រី ឪពុកម្ដាយកូន ឬស្រែចម្ការ ព្រោះតែខ្ញុំនិងព្រោះតែដំណឹងល្អ
៣០ អ្នកនោះនឹងទទួលក្នុងពេលឥឡូវនេះ មួយជាមួយរយ
គឺផ្ទះសម្បែង បងប្អូនប្រុសស្រី ម្ដាយកូន និងស្រែចម្ការ
ព្រមទាំងទទួលការបៀតបៀន
ហើយក៏នឹងមានជីវិតអស់កល្បជានិច្ចនៅលោកខាងមុខថែមទៀតផង។

គ.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ព្រះយេស៊ូជាងទ្រនំសុខរបស់ខ្លួន
C. A DISCIPLE OF JESUS LOVES JESUS MORE THAN HIS COMFORT
លូកា ១៤:២៧
២៧ អ្នកណាមិនលី ឈើឆ្កាងរបស់ខ្លួន មកតាមខ្ញុំទេ
អ្នកនោះក៏ពុំអាចធ្វើជាសិស្សរបស់ខ្ញុំបានដែរ។

លីឈើឆ្កាងរបស់ខ្លួនមកតាមព្រះយេស៊ូ CARRY ONE’S CROSS AND FOLLOW JESUS
គឺសុខចិត្តលះបង់ផ្ទះសម្បែង( be willing to leave his home ) សន្តិសុខ( his security )
សុវត្ថិភាព( his safety ) ផាសុកភាព( his comfort) និងកិត្តិយសរបស់ខ្លួន( and his honor)
ដែលសាតាំងជាចៅហ្វាយរបស់មនុស្សលោក( the ruler of this world )បានផ្ដល់ឲ្យខ្លួន
មកដើរតាមព្រះយេស៊ូក្នុងឋានៈជាសិស្សរបស់ព្រះអង្គ(to follow Jesus as his disciple)
ដែលមានជីវភាពរស់នៅយ៉ាងសាមញ្ញ(who has a simple lifestyle)
ព្រោះតែព្រះយេស៊ូនិងដំណឹងល្អ(for Jesus’ sake and for the gospel)។



ព្រោះតែព្រះយេស៊ូនិងដំណឹងល្អ សិស្សរបស់ព្រះយេស៊ូម្នាក់ៗអាចនឹងបាត់បង់( may lose )
ផ្ទះសម្បែង សន្តិសុខ សុវត្ថិភាព ផាសុកភាព និងមត៌កបណ្តោះអាសន្នដែលសាតាំងជាចៅហ្វាយ
របស់មនុស្សលោកបានផ្តល់ឲ្យខ្លួនពីមុនមក។ ប៉ុន្តែគាត់នឹងបានទទួល( will gain )ផ្ទះសម្បែង
សន្តិសុខ សុវត្ថិភាព ផាសុកភាព និងមត៌កអស់កល្បជានិច្ចរួមជាមួយព្រះយេស៊ូគ្រិស្តជាអម្ចាស់។

គ១.សិស្សរបស់ព្រះយេស៊ូមានជីវភាពរស់នៅសាមញ្ញដូចព្រះយេស៊ូ

A DISCIPLE OF JESUS HAS A SIMPLE LIFSTYLE LIKE JESUS

លូកា ៩:៥៧-៥៨

៥៧ កាលព្រះយេស៊ូកំពុងយាងតាមផ្លូវជាមួយសិស្ស
មានបុរសម្នាក់ទូលព្រះអង្គថា៖
«ខ្ញុំប្របាទសុខចិត្តទៅតាមលោក ទោះបីលោកអញ្ជើញទៅទីណាក៏ដោយ»។
៥៨ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖
«សត្វកញ្ជ្រោងមានរូងរបស់វា បក្សាបក្សីក៏មានសំបុករបស់វាដែរ
ប៉ុន្តែ បុត្រមនុស្ស គ្មានទីជម្រក សម្រាកសោះឡើយ»។

គ២.សិស្សរបស់ព្រះយេស៊ូនឹងទទួលផ្ទះសម្បែងមួយជាមួយរយ

A DISCIPLE OF JESUS WILL RECEIVE A HUNDREDFOLD HOMES

ម៉ាកុស ១០:២៩-៣០

២៩ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖
«ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថាអ្នកណាលះបង់ ផ្ទះសម្បែង
បងប្អូនប្រុសស្រី ឪពុកម្ដាយកូន ឬស្រែចម្ការ ព្រោះតែខ្ញុំនិងព្រោះតែដំណឹងល្អ
៣០ អ្នកនោះនឹងទទួលក្នុងពេលឥឡូវនេះ មួយជាមួយរយ
គឺផ្ទះសម្បែង បងប្អូនប្រុសស្រី ម្ដាយកូន និងស្រែចម្ការ
ព្រមទាំងទទួលការបៀតបៀន
ហើយក៏នឹងមានជីវិតអស់កល្បជានិច្ចនៅលោកខាងមុខថែមទៀតផង។

គ៣.សិស្សរបស់ព្រះយេស៊ូនឹងមានកន្លែងផ្ទាល់ខ្លួនក្នុងដំណាក់របស់ព្រះបិតា

A DISCIPLE OF JESUS WILL HAVE HIS PLACE IN THE FATHER’S HOUSE

យ៉ូហាន ១៤:២-៣

២ ក្នុងដំណាក់របស់ព្រះបិតាខ្ញុំមាន លំនៅជាច្រើន។
បើពុំដូច្នោះទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា
ខ្ញុំទៅរៀបចំ កន្លែង ទុកឲ្យអ្នករាល់គ្នាឡើយ។
៣ ពេលខ្ញុំទៅរៀបចំកន្លែងទុកឲ្យអ្នករាល់គ្នារួចហើយ
ខ្ញុំនឹងត្រឡប់មកវិញយកអ្នករាល់គ្នាទៅជាមួយខ្ញុំ
ដើម្បីឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ។

## ឃ.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ព្រះយេស៊ូជាងទ្រព្យសម្បត្តិរបស់ខ្លួន

D. A DISCIPLE OF JESUS LOVES JESUS MORE THAN HIS WEALTH

លូកា ១៤:៣៣

៣៣ ដូច្នេះ ក្នុងចំណោមអ្នករាល់គ្នា បើអ្នកណាមិនលះបង់ អ្វីៗទាំងអស់ ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសិស្សរបស់ខ្ញុំបានឡើយ»។

ស្រឡាញ់ព្រះយេស៊ូជាងទ្រព្យសម្បត្តិរបស់ខ្លួន

LOVE JESUS MORE THAN ONE'S WEALTH

គឺទទួលស្គាល់ថាខ្លួនបានទទួលពរគ្រប់ប្រការពីព្រះជាម្ចាស់តាមរយៈព្រះយេស៊ូ (Acknowledge that one is blessed in every way through Jesus)។ សិស្សរបស់ព្រះយេស៊ូជឿ( believe ) ឲ្យតម្លៃ( esteem ) និងចាត់ទុក( regard )ព្រះគ្រិស្តជាព្រះអង្គវិសេសជាងទ្រព្យសម្បត្តិរបស់ខ្លួន( Jesus is more precious than one's wealth )។ ព្រោះតែព្រះយេស៊ូនិងដំណឹងល្អ គាត់សុខចិត្តថ្វាយទ្រព្យសម្បត្តិរបស់ខ្លួនដោយចិត្តរីករាយ។

## ឃ១.សិស្សរបស់ព្រះយេស៊ូមិនគោរពបម្រើម្ចាស់ពីរទេ

A DISCIPLE OF JESUS DOES NOT SERVE TWO MASTERS

លូកា ១៦:១៣

១៣ គ្មានអ្នកណាអាចបំរើម្ចាស់ពីរនាក់បានទេព្រោះអ្នកនោះនឹងស្អប់ម្នាក់ស្រឡាញ់ម្នាក់ ស្មោះត្រង់នឹងម្នាក់មើលងាយម្នាក់ទៀតពុំខាន។ អ្នករាល់គ្នាពុំអាចគោរពបំរើ ព្រះជាម្ចាស់ ផង គោរពបំរើ ទ្រព្យសម្បត្តិលោកីយ៍ ផងបានឡើយ»។



**ពាក្យព្រមាន** WARNING

ទឹកអាចបណ្តែតទូកក៏បាននិងអាចពន្លិចទូកក៏បាន។
ភ្លើងអាចចម្អិនម្ហូបក៏បាននិងអាចកម្លោចម្ហូបក៏បាន។
លុយអាចជាបម្រើអ្នកក៏បាននិងអាចជាព្រះអ្នកក៏បាន
គឺវាអាស្រ័យលើចំណុចមួយនេះថា៖
«តើអ្នកកំពុងគ្រប់គ្រងលុយឬលុយកំពុងគ្រប់គ្រងអ្នក ?»

យ២.សិស្សរបស់ព្រះយេស៊ូទទួលពររួមជាមួយលោកអប្រាហាំ
A DISCIPLE OF JESUS IS BLESSED ALONG WITH ABRAHAM
កាឡាទី ៣:៧,៩,១៤
៧ ក្នុងដូច្នេះសូមបងប្អូនយល់ថាអ្នកណាមានជំនឿ
អ្នកនោះហើយជាកូនចៅរបស់លោកអប្រាហាំ។
៩ ហេតុនេះ អស់អ្នកដែលមានជំនឿ
ក៏ បានទទួលព្រះពរ រួមជាមួយលោកអប្រាហាំ
ដែលជាអ្នកមានជំនឿនោះដែរ។
១៤ ហេតុការណ៍នេះកើតមានដូច្នេះ
ដើម្បីឲ្យព្រះពរដែលលោកអប្រាហាំទទួល
បានហូរទៅដល់សាសន៍ដទៃតាមរយៈព្រះគ្រិស្តយេស៊ូដែរ
ហើយឲ្យយើងទទួលព្រះវិញ្ញាណ
ដែលព្រះជាម្ចាស់បានសន្យាប្រទានមកដោយយើងមានជំនឿ។

យ៣.សិស្សរបស់ព្រះយេស៊ូជាអ្នកទទួលពរផងនិងជាអ្នកផ្ដល់ពរផង
A DISCIPLE OF JESUS IS BLESSED TO BE A BLESSING
២កូរិនថូស ៩:៨-៩
៨ ព្រះអង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន
ដើម្បីឲ្យបងប្អូន មាន អ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏ចាំបាច់នោះជានិច្ច
ហើយថែមទាំងនៅសល់បរិបូណ៌សំរាប់ ចែកទាន ផង
៩ ដូចមានចែងទុកមកថា:«ព្រះអង្គចែក ព្រះអង្គប្រទានឲ្យអ្នកក្រ
សេចក្ដីសុចរិតរបស់ព្រះអង្គនៅស្ថិតស្ថេររហូតតរៀងទៅ»។

ក្នុងនាមជាអ្នកផ្ដល់ពរ AS A BLESSING
សិស្សរបស់ព្រះយេស៊ូអាចថ្វាយកម្លាំង(strength) ពេលវេលា(time) ការងារ(work)
ជំនាញ(skills) ឬទ្រព្យសម្បត្តិ(wealth)ដូចជាប្រាក់កាស ម្ហូបអាហារ ដីធ្លី ផ្ទះសម្បែង
របស់ខ្លួន ។ល។ សម្រាប់ការផ្សព្វផ្សាយដំណឹងល្អ( for evangelism )
និងការពន្លឿនព្រះរាជ្យរបស់ព្រះជាម្ចាស់( the acceleration of the kingdom of God ) ។

## ង.សិស្សរបស់ព្រះយេស៊ូស្រឡាញ់គ្នាទៅវិញទៅមក
## E. A DISCIPLE OF JESUS LOVES ONE ANOTHER

យ៉ូហាន ១៣:៣៤-៣៥
៣៤ ខ្ញុំឲ្យបទបញ្ញាថ្មីដល់អ្នករាល់គ្នាគឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។
អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។
៣៥ បើអ្នកស្រឡាញ់ គ្នាទៅវិញទៅមក
មនុស្សទាំងអស់មុខជាដឹងថាអ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន»។

ស្រឡាញ់គ្នាទៅវិញទៅមក LOVE ONE ANOTHER
គឺយល់( understand )និងចាក់ឫសមាំមួនក្នុង( be deeply rooted in )សេចក្ដីស្រឡាញ់របស់ព្រះគ្រិស្ត(the love of Christ)ជាសេចក្ដីស្រឡាញ់ដ៏ខ្លាំងក្លា( great) អស់កល្ប( eternal) ឥតលក្ខខណ្ឌ( unconditional) ឥតព្រំដែន( unlimited) និងមិនអាចបំបែកបាន(inseparable) ហើយប្ដេជ្ញាចិត្ត(commit)ថាស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះគ្រិស្តបានស្រឡាញ់យើងដែរ។



ទោះបីជាសិស្សដទៃទៀតរបស់ព្រះយេស៊ូមានរឿងរ៉ាវជាមួយយើងក៏ដោយ
( ស្អប់ខ្ពើម hate ឈ្លោះប្រកែក quarrel មួលបង្កាច់ accuse ទម្លាក់កំហុស blame
ប្រមាថមើលងាយ insult បៀតបៀន persecute ចងគំនុំ hold a grudge ។ល។)
ក៏យើងប្ដេជ្ញាចិត្តថាអត់ទោសឲ្យគាត់ហើយស្រឡាញ់គាត់ដូចព្រះគ្រិស្តបានស្រឡាញ់យើងដែរ។

## ច.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ការពហុគុណ

F. A DISCIPLE OF JESUS LOVES MULTIPLICATION

យ៉ូហាន ១៥:៨

[៨] ព្រះបិតារបស់ខ្ញុំសម្តែងសិរីរុងរឿង
ដោយអ្នករាល់គ្នា បង្កើតផលផ្លែបានច្រើន និងដោយអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន។

ស្រឡាញ់ការពហុគុណ LOVE MULTIPLICATION
គឺបង្កើតផលជាច្រើនដើម្បីតម្កើងសិរីរុងរឿងរបស់ព្រះបិតាដោយសារការពហុគុណ
( Bear much fruit to glorify the Father by multiplication)
គឺការបង្កើតសិស្សពីជំនាន់មួយទៅជំនាន់មួយទៀត ។
( making disciples from one generation to another )
ព្រះយេស៊ូសព្វព្រះហឫទ័យឲ្យសិស្សម្នាក់ៗពហុគុណតាមសណ្ឋានឬទ្រង់ទ្រាយរបស់ខ្លួន ។
( Jesus wants each of his disciples to multiply according to one’s SHAPE )



មែកទំពាំងបាយជូរ( សិស្សព្រះយេស៊ូ )ដែលនៅជាប់នឹងដើមទំពាំងបាយជូរ( ព្រះយេស៊ូ )
បង្កើតផលជាផ្លែទំពាំងបាយជូរជាច្រើន( បង្កើតសិស្សជាច្រើននាក់និងជាច្រើនជំនាន់ )
ដើម្បីកៀបយកទឹកទំពាំងបាយជូរទៅបិតស្រាទំពាំងបាយជូរ( លោហិតនៃសម្ពន្ធមេត្រីថ្មី ) ។



ព្រះយេស៊ូចាត់សិស្សរបស់ព្រះអង្គឲ្យទៅបង្កើតផលនៃព្រះវិញ្ញាណ( កាឡាទី ៥:២២-២៣ ) ផលនៃបបូរមាត់របស់ខ្លួន( ហេប្រឺ ១៣:១៥ ) ផលនៃពន្លឺ( អេភេសូ ៥:៨-៩ ) ផលនៃសេចក្តីសុចរិត( ភីលីព ១:១១ ) និងផលនៃកិច្ចការដោយដៃរបស់ខ្លួន( ទំនុកតម្កើង ១២៨:២-៤ )។

ឆ.សិស្សរបស់ព្រះយេស៊ូស្រឡាញ់ការរៀបផែនការឈ្លាសវៃ
G. A DISCIPLE OF CHRIST LOVES SMART PLANNING

ឆ១.ការរៀបផែនការឈ្លាសវៃជួយយើងឲ្យចាប់ផ្តើមយ៉ាងល្អហើយបញ្ចប់យ៉ាងល្អ
SMART PLANNING HELPS US BEGIN WELL AND FINISH WELL

លូកា ១៤:២៨-៣០
២៨ ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើនរណាម្នាក់ចង់សង់ផ្ទះថ្មធំមួយ
អ្នកនោះត្រូវអង្គុយគិតគូរមើលថ្លៃសង់ជាមុនសិន
ដើម្បីឲ្យដឹងថាតើខ្លួនមានប្រាក់ល្មមនឹងបង្ហើយសំណង់ឬយ៉ាងណា
២៩ ក្រែងលោចាក់គ្រឹះហើយតែមិនអាចបង្ហើយបាន
មនុស្សម្នាឃើញមុខជាសើចចំអកឲ្យមិនខាន។
៣០ គេនឹងពោលថា "មើលបុរសនេះសង់ផ្ទះតែមិនអាច បង្ហើយ បានទេ!"។

ការធ្វើជាសិស្សរបស់ព្រះយេស៊ូគឺជាការប្តូរផ្តាច់នៅជាប់នឹងព្រះយេស៊ូហើយរៀនពីព្រះអង្គអស់មួយជីវិតដើម្បីកសាងជីវិតខ្លួនឲ្យបានល្អនៅលើគ្រឹះដ៏រឹងមាំនិងដើម្បីបញ្ចប់ជីវិតខ្លួនឲ្យបានល្អ។



ព្រះយេស៊ូបង្គាប់( commands )សិស្សម្នាក់ៗឲ្យសាងសង់ផ្ទះជីវិតមួយ(a house of life)
ដែលមានលក្ខណៈរឹងមាំ(firm) ធំទូលាយ(spacious) ខ្ពស់ស្រឡះ(high) គត់មត់(intact)
និងមិនងាយដួលរលំ(not easy to fall apart)។ ដើម្បីសម្រេចគោលបំណងនេះ
សិស្សត្រូវមានផែនការឈ្លាសវៃមួយ(a SMART plan)ទើបអាចបញ្ចប់ការសាងសង់បានល្អ។

## ឆ១.ការរៀបផែនការឈ្លាសវៃជួយយើងឲ្យប្រយុទ្ធយ៉ាងល្អហើយឈ្នះយ៉ាងល្អ
SMART PLANNING HELPS US FIGHT WELL AND WIN WELL

លូកា ១៤:៣១-៣២

៣១ ម្យ៉ាងទៀត ប្រសិនបើមានស្តេចមួយអង្គ
ចេញទៅធ្វើសឹកសង្គ្រាមតទល់នឹងស្តេចមួយអង្គទៀត
ទ្រង់ត្រូវគង់គិតគូរជាមុនសិនថាបើទ្រង់មានទ័ពមួយម៉ឺននាក់
តើទ្រង់ អាចតទល់ នឹងបច្ចាមិត្តដែលមានគ្នាពីរម៉ឺននាក់បានឬយ៉ាងណា
៣២ បើឃើញថាមិនអាចតទល់បានទេ
នោះទ្រង់នឹងចាត់រាជទូតឲ្យទៅសុំចរចារកសន្តិភាព
ក្នុងពេលដែលស្តេចមួយអង្គទៀតនៅឆ្ងាយនៅឡើយ។

ការធ្វើជាសិស្សរបស់ព្រះយេស៊ូគឺជាការប្តូរផ្តាច់នៅជាប់នឹងព្រះយេស៊ូហើយពឹងផ្អែកលើព្រះអង្គ
អស់មួយជីវិតដើម្បីយកឈ្នះយ៉ាងល្អលើសត្រូវដែលតែងតែរិះរកឱកាសវាយប្រហារខ្លួនជានិច្ច។



ព្រះយេស៊ូលាបប្រេងអភិសេក( anoints )សិស្សម្នាក់ៗជាក្សត្រនិងបូជាចារ្យមួយអង្គ ដែលត្រូវប្រឈមនឹងសង្គ្រាមវិញ្ញាណ(spiritual warfare)ក្នុងជីវិតនិងព័ន្ធកិច្ចរបស់ខ្លួន (in one's life and one's ministry)ជារៀងរាល់ថ្ងៃ។ ដើម្បីសម្រេចគោលបំណងនេះ សិស្សត្រូវមានផែនការឈ្លាសវៃមួយ( a SMART plan )ទើបអាចយកឈ្នះសត្រូវបានល្អ។

## ៤.ភាពខុសប្លែកគ្នារវាងការសង្គ្រោះនិងការបង្កើតសិស្ស
## 4. THE DIFFERENCE BETWEEN SALVATION AND DISCIPLESHIP

| ការសង្គ្រោះ SALVATION | ការបង្កើតសិស្ស DISCIPLESHIP |
|---|---|
| ឥតគិតថ្លៃ | គិតថ្លៃ |
| យើងទទួលពីព្រះយេស៊ូដោយជំនឿ | យើងប្តូរផ្តាច់ស្តាប់បង្គាប់ព្រះយេស៊ូ |
| មិនពាក់ព័ន្ធនឹងការប្រព្រឹត្តទេ | ពាក់ព័ន្ធនឹងការប្រព្រឹត្ត |
| យើងទទួលការប្រោសឲ្យសុចរិតភ្លាម | យើងទទួលការលាងជម្រះរៀងរាល់ថ្ងៃ |
| ព្រះយេស៊ូចេញថ្លៃជំនួស | សិស្សបង់ថ្លៃដោយខ្លួនឯង |
| មករកព្រះយេស៊ូជាព្រះសង្គ្រោះ | ដើរតាមព្រះយេស៊ូជាព្រះអម្ចាស់ |
| ជឿលើដំណឹងល្អរបស់ព្រះយេស៊ូ | ប្រតិបត្តិតាមបញ្ញារបស់ព្រះយេស៊ូ |
| ទទួលការសង្គ្រោះដោយសារព្រះគុណ | រីកចម្រើនឡើងដោយសារព្រះគុណ |

Simply By Grace: The Distinctions Of Discipleship, Page 121, Charles C. Bing, 2009

## ៥.ព្រះយេស៊ូចាត់យើងឲ្យចេញទៅបង្កើតសិស្ស

5. JESUS SENDS US TO GO AND MAKE DISCIPLES

ម៉ាថាយ ១៨:១៨-២០

១៨ ព្រះយេស៊ូយាងចូលមកជិតគេហើយមានព្រះបន្ទូលថា៖
«ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី។
១៩ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជា សិស្ស
ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។
២០ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។
ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃរហូតដល់អវសានកាលនៃពិភពលោក»។

ព្រះយេស៊ូមិនគ្រាន់តែត្រាស់ហៅយើងឲ្យមកធ្វើជាសិស្សរបស់ព្រះអង្គប៉ុណ្ណោះទេ
(Jesus did not only call us to be his disciples)
ព្រះអង្គថែមទាំងចាត់យើងឲ្យចេញទៅបង្កើតសិស្ស(but also sends us to make disciples)
ដើម្បីពន្លឿនព្រះរាជ្យរបស់ព្រះជាម្ចាស់ឲ្យឆាប់មកដល់លើផែនដីនេះ។

សំណួរបញ្ជាក់ការអនុវត្ត

1. តើអ្នកបានធ្វើជាសិស្សរបស់ព្រះយេស៊ូឬនៅ? ធ្វើតាំងពីពេលណាមក?
   តើអ្នកបានអ្នកណាជួយបណ្ដុះបណ្ដាលអ្នក?
2. តើអ្នកស្រឡាញ់ព្រះបន្ទូលរបស់ព្រះយេស៊ូដោយរបៀបណា?
3. តើអ្នកស្រឡាញ់ព្រះយេស៊ូជាងគ្រួសាររបស់អ្នកដោយរបៀបណា?
4. តើអ្នកស្រឡាញ់ព្រះយេស៊ូជាងទ្រនំសុខរបស់អ្នកដោយរបៀបណា?
5. តើអ្នកស្រឡាញ់ព្រះយេស៊ូជាងទ្រព្យសម្បត្តិរបស់អ្នកដោយរបៀបណា?
6. តើអ្នកស្រឡាញ់គ្នាទៅវិញទៅមកដោយរបៀបណា( គិតទាំងអ្នកដែលស្អប់ខ្ពើមអ្នក )?
7. តើអ្នកស្រឡាញ់ការពហុគុណ( ការបង្កើតផល )ដោយរបៀបណា?
8. តើអ្នកស្រឡាញ់ផែនការឈ្លាសវៃដល់កម្រិតណា?
   តើអ្នកមានផែនការបែបណាដើម្បីឲ្យក្លាយជាសិស្សដែលរីកចម្រើនគ្រប់វិស័យ?
9. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ ម៉ាថាយ ១១:២៨-៣០។